ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

វិច្ឆិកា ២០០៥ / November 2005

កញ្ញា អ៊ុច ច័ន្ទតារានី / **Ms. Ouch Chandarany**

លោកស្រី ប៉ុន ដូរីណា / **Ms. Pon Dorina**

លោក ហ៊ីង វុទ្ធា / **Mr. Hing Vutha**

លោក ភីម រុនស៊ីណារិទ្ធ / **Mr. Phim Runsinarith**

បកប្រែដោយៈ យូ សិទ្ធីរិទ្ធ

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Tel/fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh *Website:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

នៅត្រីមាសទី២ ២០០៥ វិនិយោគសាធារណៈនៅកម្ពុជាមាន ៦៥លានដុល្លារ រឺ ៤,៦% ច្រើនជាងត្រីមាសមុន និង ២២,៦% តិចជាងត្រីមាសទី២ ឆ្នាំមុន ក្នុងនេះវិនិយោគសាធារណៈដោយទុនក្នុងស្រុកមាន ២០,២លានដុល្លារ រឺថយចុះ ២៣,៧% ធៀបនឹងត្រីមាសទី២ ឆ្នាំមុន ។ វិនិយោគឯកជនគិតជាទ្រព្យសកម្មជាប់លាប់ដែល CDC អនុម័ត មាន ៩៦,១លានដុល្លារ ។

In the second quarter of 2005, public investment in Cambodia amounted to about $65 million, 4.6 percent more than in the preceding quarter, but 22.6 percent less than in the same quarter last year. Public investment from domestic financing accounted for $20.2 million in the April-June quarter, a decrease of 23.7 percent from the same period last year, while the remaining $44.8 million was from external assistance, a 22.2 percent reduction. The value of private investment in terms of fixed asset approvals by CDC totalled $96.1 million in the second quarter, a drop of nearly 80 percent from the first quarter, and of 15 percent from second quarter 2004.

**Public and Private Investment**
(US$ million)




*Note: Data for May–-June 2005 exclude expansion project approvals.*
Source: Council for the Development of Cambodia

នៅត្រីមាសទី៣ ២០០៥ ភ្ញៀវមកដល់ខេត្តសៀមរាបតាមគ្រប់មធ្យោបាយដឹកជញ្ជូនមាន ១៧៩.៤១២នាក់ រឺ ១៦,៧%តិចជាងត្រីមាសទី២ ។ ធៀបនឹងត្រីមាសទី៣ ឆ្នាំមុន ភ្ញៀវមកដល់សរុប កើន ៧,៥% ។ ក្នុងនេះ ភ្ញៀវបរទេសមកដល់ កើន ២១% ដល់ ១៥៤.០៧៨នាក់ ចំណែកឯភ្ញៀវកម្ពុជាថយចុះ ៣៦% មកត្រឹម ២៥.៣៣៤នាក់ ។

In the third quarter of 2005, visitor arrivals to Siem Reap province, using all types of transportation, totalled 179,412 persons, a decrease of 16.7 percent from the second quarter. Compared to the third quarter last year, however, total arrivals to Siem Reap rose by 7.5 percent. Foreign arrivals showed a 21 percent increase (to 154,078 persons), while Cambodian visitors declined by 36 percent (to 25,334 persons).

**Cambodian and Foreign Visitor Arrivals to Siem Reap Province (all modes of transportation)** (thousand persons)




*Note: Latest data available are for September 2005.*
Source: Ministry of Tourism

នៅខែសីហា ២០០៥ តំលៃនៃគំរោងសាងសង់ដែលបានអនុម័តនៅភ្នំពេញបន្តថយចុះអស់ ២៣,៨% បើធៀបនឹងខែមុនដល់ ២៤,៨លានដុល្លារ ។ ប៉ុន្តែបើធៀបនឹងខែដូចគ្នាឆ្នាំ២០០៤ វាកើនឡើង ២០,៤% ក្នុងនេះ តំលៃភូមិគ្រឹះ និងផ្ទះ កើន ១២,៥% ដល់ ៣,១លានដុល្លារ, តំលៃសំណង់ផ្សេងៗទៀតកើន ៨៩% ដល់ ១០,២លានដុល្លារ រីឯតំលៃសំណង់ផ្ទះល្វែងថយចុះ ៧,៥% មកត្រឹម ១១,៥លានដុល្លារ ។

The value of construction project approvals in Phnom Penh in August 2005 continued downward from the preceding month, declining by 23.8 percent to $24.8 million. Compared to the same month of 2004, the value of construction project approvals rose by 20.4 percent, of which the value of villas and houses and other projects grew by 12.5 percent to $3.1 million and by 89 percent to $10.2 million respectively. The value of flat construction approvals was down 7.5 percent, to $11.5 million.

**Value of Construction Project Approvals in Phnom Penh** (US$ million)




*Note: Latest data available are for August 2005.*
Source: Department of Cadastre and Geography, Phnom Penh municipality

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

នៅខែតុលា ថ្លៃសាំង និងម៉ាស៊ូត បន្តកើនឡើងនៅភ្នំពេញ ដោយមានកំរិតជាមធ្យម ៣.៧៦៨,៥រៀល/លីត្រ និង ២.៩៥០រៀល/លីត្ររៀងគ្នា ធៀបនឹងកំរិត ៣.៧២០៛/លីត្រ និង ២.៩១៨៛/លីត្រ កាលពីខែកញ្ញា ។ កំណើននេះបណ្តាលជាសំខាន់មកពីការចុះថ្លៃប្រាក់រៀលទល់នឹងដុល្លារ ពីព្រោះថ្លៃសាំង និងម៉ាស៊ូត គិតជាដុល្លារ គ្មានការប្រែប្រួលទេនៅភ្នំពេញ ។

The prices of gasoline and diesel oil in Phnom Penh in October continued to rise. The prices averaged 3,768.5 and 2,950 riels/litre in October respectively, from 3,720 and 2,918 riels/litre in September. The increases were mainly related to the riel's depreciation against the dollar, while gasoline and diesel prices in dollars in Phnom Penh remained unchanged.

**Prices of Gasoline and Diesel Oil in Phnom Penh**




Sources: CDRI and National Institute of Statistics

នៅខែកញ្ញា ថ្លៃទំនិញប្រើប្រាស់ជាទូទៅនៅភ្នំពេញ មានកំរិត ៥% ខ្ពស់ជាងកាលពីមួយឆ្នាំមុន ធៀបនឹងកំណើនប្រចាំឆ្នាំ ៤,៥% នៅខែសីហា ។ ថ្លៃម្ហូបអាហារ កើន ៦,៧% ក្នុងរយៈមួយឆ្នាំ ដល់ចុងខែកញ្ញា រីឯថ្លៃដឹកជញ្ជូនកើន ១២,៩% ។

In September, overall consumer prices in Phnom Penh were 5 percent higher than a year earlier, compared to a 4.5 percent year-on-year rise in the preceding month. Food prices rose 6.7 percent in the year to September, and the cost of transportation rose 12.9 percent.

**Consumer Price Index**

(July–December 2000=100)




*Note: Latest data available are for September 2005.*
Source: National Institute of Statistics

ស្ថាប័នមីក្រូហិរញ្ញវត្ថុ អម្រឹត ហត្ថាកសិករ និងតុងហ្វាង គឺជាអ្នកផ្តល់ឥណទានចំបងគេ ជាពិសេសនៅជនបទកម្ពុជា ។ គិតត្រឹមចុងខែតុលា អម្រឹតផ្តល់កំចី ៤១ពាន់លានរៀល ហត្ថាកសិករ ១២,៦ពាន់លានរៀល និងតុងហ្វាង ០,៤ពាន់លានរៀល ធៀបនឹងកំរិត ២៨ពាន់លានរៀល, ៧,៨ពាន់លានរៀល និង ០,៣ពាន់លានរៀលនៅចុងខែតុលាឆ្នាំមុន ។

Amret, Hattha Kaksekar and Tong Fang micro-finance institutions are major credit providers, especially to rural areas of Cambodia. Amret had loans of about 41 billion riels at the end of August 2005, at a 42 percent per year interest rate, a rise from 28 billion riels at the end of August 2004, on which it charged 48 percent interest per annum. Hattha Kaksekar had 12.6 billion riels outstanding at the end of August 2005, compared to 7.8 billion riels at the end of the same month last year. Credits provided by Tong Fang were about 0.4 billion riels, compared with about 0.3 billion riels a year earlier, on which it charged a 12-month interest rate of 36 percent.

**Credit Provided By Three Major Micro-Finance Institutions**

(billion riels)




Source: National Bank of Cambodia

# ស្ថានភាពអត្រាប្តូរប្រាក់និងរូបិយវត្ថុ

# Exchange Rate and Monetary Developments

ទល់នឹងដុល្លារ ប្រាក់រៀលឡើងចុះបន្តិចបន្តួចនៅខែតុលា ក្នុងកំរិតលើសពី ៤.២០០រ/ដុល្លារបន្តិច ។ ប៉ុន្តែ គិតជាមធ្យម អត្រាប្តូរប្រាក់ទីផ្សារនៅខែតុលា សឹងគ្មានការប្រែប្រួល បើធៀបនឹងខែកញ្ញា ក្នុងកំរិតប្រហែល ៤.២០៧រ/ដុល្លារ ។

Against the US dollar, the riel fluctuated slightly above 4,200 riels/dollar in October. On average, however, the market rate in October remained almost unchanged from September, at around 4,207 riels/dollars.

**Riels per US Dollar**




Sources: National Bank of Cambodia and CDRI

នៅខែតុលា ប្រាក់រៀលសឹងគ្មានការប្រែប្រួល ទល់នឹងប្រាក់បាតថៃ និងដុងវៀតណាម បើធៀបនឹងខែកញ្ញា ដោយប្តូរបាន ១០២,៨រៀល/បាត រឺ ២៦,៥រៀល/១០០ដុង ។

Against both the Thai baht and the Vietnamese dong, the riel remained mostly unchanged in October 2005, compared to the preceding month. One baht bought 102.8 riels, and 100 dongs were worth 26.5 riels.

**Riels per Thai Baht and 100 Vietnamese Dong**




Source: CDRI

នៅខែសីហា រូបិយវត្ថុទូទៅថយចុះបន្តិច អស់ ០,៤% ធៀបនឹងកក្កដា ដល់ ៤.៧៦៣,៣ពាន់លានរៀល ។ ការថយចុះប្រាក់បញ្ញើជារូបិយវត្ថុបរទេស អស់ ០,៨% នាំឱ្យរូបិយវត្ថុទូទៅថយចុះ ។ ប៉ុន្តែក្នុងរយៈពេលនេះ ប្រាក់បញ្ញើជារៀលនៅធនាគារ និងប្រាក់រៀលនៅក្រៅធនាគារ កើន ២,៤% និង ០,៧% រៀងគ្នា ។

In August, total liquidity declined slightly by 0.4 percent compared to July, to 4,763.3 billion riels. A decline of 0.8 percent in foreign currency deposits led the decrease in total liquidity. However, during this time, riels in bank deposits and outside banks rose by 2.4 percent and 0.7 percent, respectively.

**Liquidity of the Banking System**
(billion riels)




*Note: Latest data available are for August 2005.*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

នៅខែសីហា ការនាំចេញរបស់កម្ពុជាមានសរុប ២២០,៦លានដុល្លារ រឺថយចុះ ១៣,៥% ធៀបនឹងខែមុន និងថយចុះ ១០,២% ធៀបនឹងខែសីហាឆ្នាំមុន ។ ក្នុងនេះ សំលៀកបំពាក់នាំចេញ ថយចុះ ៩,២% ដល់ ២១៤,៧ លានដុល្លារ ហើយទំនិញនាំចេញចំបង៧បីមុខទៀតគឺ កៅស៊ូ អង្ករ និង ត្រីក៏ថយចុះដែរ ។

Cambodia’s total exports were $220.6 million in August, a 13.5 percent decrease compared to the preceding month. Likewise, total exports declined by 10.2 percent from August last year. Garment exports fell by 9.2 percent to $214.7 million. Three other major exports, rubber, rice and fish, also declined.

## Cambodia’s Main Exports

(US$ million)




*Note: Latest data available are for August 2005.*
Source: Customs and Excise Department

នៅខែសីហា ការនាំចូលស៊ីម៉ង់ត៍ និងដែក មានតំលៃ ១៧,២ពាន់លានរៀល និង ១៣,១ពាន់លានរៀលរៀងគ្នា ។ ធៀបនឹងខែដូចគ្នាឆ្នាំមុន ស៊ីម៉ងត៍នាំចូលកើន ៣៥,៧% ឯដែកនាំចូលកើនជិតមួយជាប្រាំ ។ បារីនាំចូលដែលមានតំលៃ ៣២,៤ពាន់លានរៀលនៅខែសីហា ២០០៥ គឺបានថយចុះ ៩% បើធៀបនឹងកាលពីមួយឆ្នាំមុន ។

The value of cement and steel imports amounted to 17.2 billion riels and 13.1 billion riels respectively in August. Compared to the same month last year, cement imports rose by 35.7 percent, and steel imports increased nearly five times. Imports of cigarettes, which were valued at 32.4 billion riels in August 2005, were down 9 percent from a year earlier.

## Imports of Cigarettes and Construction Materials

(billion riels)




*Note: Latest data available are for August 2005.*
*(Excluding public sector imports).*
Source: Customs and Excise Department

នៅខែសីហា កម្ពុជាបាននាំចូលម៉ាស៊ូត ២៣,២ពាន់លានរៀល និងសាំង ១៣,៩ពាន់លានរៀល ។ ធៀបនឹងខែសីហា ២០០៤ តំលៃម៉ាស៊ូតនាំចូលថយចុះ ១៥,៤% ប៉ុន្តែសាំងនាំចូល កើន ១៦,៧% ។

In August, Cambodia imported a total of 23.2 billion riels of diesel oil and 13.9 billion riels of gasoline. Diesel imports were down 15.4 percent from August 2004. In contrast, the value of gasoline imports increased by 16.7 percent.

## Imports of Petroleum Products

(billion riels)




*Note: Latest data available are for August 2005.*
*(Excluding public sector imports).*
Source: Customs and Excise Department

# ប្រភពនិងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

នៅឆ្នាំ២០០៥ ខេត្តតាកែវ ទទួលបានទឹកប្រាក់ច្រើនជាងគេក្នុងលំដាប់ទី៤ ពីមូលនិធិឃុំ/សង្កាត់ គឺនៅក្រោមតែ កំពង់ចាម កណ្តាល និងព្រៃវែង ប៉ុណ្ណោះ ។ ធៀបនឹងឆ្នាំ២០០៤ មូលនិធិឃុំ/សង្កាត់ សំរាប់ខេត្តតាកែវ កើន ១៣,៤% ដល់ ៤,៣ពាន់លានរៀលនៅឆ្នាំ២០០៥ ក្នុងនេះ ៦៧% (២,៩ ពាន់លានរៀល) គឺសំរាប់អភិវឌ្ឍន៍ និង ៣៣% (១,៤ពាន់លានរៀល) សំរាប់ខាងរដ្ឋបាល ។

Takeo province received the fourth largest amount from the commune/sangkat fund in 2005, after Kompong Cham, Kandal and Prey Veng provinces. Compared to 2004, the commune/sangkat funds for Takeo increased by 13.4 percent to 4.3 billion riels in 2005, of which 67 percent (2.9 billion riels) was for development, and 33 percent (1.4 billion riels) was for administration.

=

**2005 Commune/Sangkat Fund Allocation to Takeo Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

បន្ទាប់ពីខេត្តតាកែវគឺ បាត់ដំបង ដែលទទួលបានប្រហែល ៤,២ពាន់លានរៀលពីមូលនិធិឃុំ/សង្កាត់នៅឆ្នាំ២០០៥ ។ ធៀបនឹងឆ្នាំមុន មូលនិធិផ្តល់អោយខេត្តបាត់ដំបង កើន ១៣,៧% ក្នុងនេះ ទឹកប្រាក់សំរាប់អភិវឌ្ឍន៍ កើន ១៦,៨% ដល់ ២,៩ពាន់លានរៀល និងសំរាប់ខាងរដ្ឋបាល កើន ៧,៤% ដល់ ១,៣ពាន់លានរៀល ។

Coming after Takeo province was Battambang, which received about 4.2 billion riels of commune/sangkat funds in 2005. Compared to the previous year, funds provided to Battambang rose by 13.7 percent. Allocations for development increased by 16.8 percent to 2.9 billion riels. Administration funds were up 7.4 percent, to 1.3 billion riels.

**2005 Commune/Sangkat Fund Allocation to Battambang Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

នៅឆ្នាំ២០០៥ ខេត្តសៀមរាបទទួលបានជាង ៤ពាន់លានរៀលបន្តិច ពីមូលនិធិឃុំ/សង្កាត់ នៅក្នុងនេះ មានប្រហែល ២,៨ពាន់លានរៀល គឺសំរាប់អភិវឌ្ឍន៍ និងជាង ១,២ពាន់លានរៀលសំរាប់ខាងរដ្ឋបាល ។ ធៀបនឹងឆ្នាំ២០០៤ មូលនិធិឃុំ/សង្កាត់ ផ្តល់ឱ្យខេត្តសៀមរាប កើន ១៤,៨% ក្នុងនេះ ទឹកប្រាក់សំរាប់អភិវឌ្ឍន៍កើន ១៨,៦% និងសំរាប់ខាងរដ្ឋបាលកើន ៧% ។

Siem Reap province was allocated slightly more than 4 billion riels from the commune/sangkat fund in 2005, of which about 2.8 billion riels were for development and more than 1.2 billion riels for administration. Compared to 2004, commune/sangkat funds allocated to Siem Reap expanded by 14.8 percent. There was a 18.6 percent increase for development and a 7 percent increase in administration.

**2005 Commune/Sangkat Fund Allocation to Siem Reap Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅខែកក្កដា ២០០៥ ប្រតិបត្តិការថវិកាចរន្តមានឱនភាព ៦២,៧ពាន់លានរៀល ធៀបនឹងអតិរេក ៥៦,៥ពាន់លានរៀលនៅខែមិថុនា ។ ពីខែមករា-កក្កដា ២០០៥ ប្រតិបត្តិការថវិកាចរន្ត មានអតិរេក ៤៥៦ពាន់លានរៀល ធៀបនឹងអតិរេក ៥៤០ពាន់លានរៀលក្នុងកំឡុងពេលដូចគ្នាឆ្នាំមុន ។

Current budget operations showed a deficit of 62.7 billion riels in July 2005, in contrast to a surplus of 56.5 billion riels in June. From January to July 2005, the current budget operated a surplus of 456 billion riels, compared to 540 billion riels during the same period last year.

**Current Budget Operations**
(billion riels)




*Note: Provisional for 2004 and Jan–July 2005.*
Source: Ministry of Economy and Finance

ចំណូលថវិកាចរន្តមាន ១៨៩,៣ពាន់លានរៀលនៅខែកក្កដា រឺ ១៧,៣% តិចជាងខែមុន ។ ក្នុង ៧ខែដើមឆ្នាំ២០០៥ ចំណូលចរន្តមាន ១.៣៥២ពាន់លានរៀល រឺ ៥៩% នៃផែនការឆ្នាំ២០០៥ រឺ ១៨% ច្រើនជាងកំឡុងពេលដូចគ្នាឆ្នាំ២០០៤ ក្នុងនេះចំណូលពន្ធនាំចេញ-នាំចូល កើន ១២,៣% ដល់ ៧៣០,៤ពាន់លានរៀល និងចំណូលមិនមែនពន្ធ កើន ២,៥% ដល់ ២៨៣,៤ ពាន់លានរៀល ។

Current budget revenue amounted to 189.3 billion riels in July, 17.3 percent less than the preceding month. During the first seven months of 2005, the government collected current revenue of 1,352 billion riels, achieving 59 percent of the 2005 target. Compared to the same period of 2004, revenue rose about 18 percent. Revenue from domestic tax increased over 50 percent to 338.2 billion riels. Revenue from import and export taxes and non-tax sources also improved, albeit slightly, by 12.3 percent to 730.4 billion riels and by 2.5 percent to 283.4 billion riels, respectively.

**Current Budget Revenue**
(billion riels)




*Note: Provisional for 2004 and Jan–July 2005.*
Source: Ministry of Economy and Finance

ចំណាយថវិកាចរន្ត (គ្មានបូកកំណែតំរូវចំណាយ) ឡើងដល់ ២៥២ពាន់លានរៀលនៅខែកក្កដា ២០០៥ រឺ ៤៦% ច្រើនជាងខែមុន ។ ក្នុង ៧ខែដើមឆ្នាំ២០០៥ ចំណាយចរន្ត មាន ៨៩៦ពាន់លានរៀល រឺ ៤៥% នៃផែនការឆ្នាំ២០០៥ រឺ ៤៧% ច្រើនជាងកំឡុងពេលដូចគ្នាឆ្នាំ២០០៤ ក្នុងនេះ ចំណាយលើរដ្ឋបាលទូទៅ កើនមួយជាពីរ រីឯចំនាយខាងការពារជាតិ និងសន្តិសុខ កើនប្រហែល ១៤,៨% ។

Current budget expenditure, excluding expenditure adjustment, reached 252 billion riels in July 2005, 46 percent more than in the previous month. During the first seven months of 2005, the government’s current spending totalled 896 billion riels, 47 percent more than during the same period of 2004, reaching only 45 percent of the target of the 2005 budget. Spending on general administration was doubled, while expenditure on defence and security rose about 14.8 percent.

**Current Budget Expenditure**
(billion riels)




*Note: Provisional for 2004 and Jan-July 2005.*
Source: Ministry of Economy and Finance

# សកម្មភាពសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែសីហា ការនាំចេញទំនិញរបស់ US កើនឡើង រីឯរបស់តំបន់អឺរ៉ូ និងជប៉ុនថយចុះ ។ ការនាំចេញរបស់ US កើន ២% ពី ៧៥,០៦ពាន់លាននៅខែកក្កដា ដល់ ៧៦,៦៧ពាន់លានដុល្លារនៅខែសីហា ក្នុងនេះការនាំចេញទំនិញជាមូលធន រថយន្ត ម៉ាស៊ីននិងគ្រឿងបន្លាស់ សំភារៈឧស្សាហកម្ម ម្ហូបអាហារនិងភេសជ្ជៈ កើនឡើង ។ ការនាំចេញរបស់តំបន់អឺរ៉ូ ថយចុះពី ៨៩,១១ពាន់លានដុល្លារនៅខែកក្កដា ដល់ ៨៣,៤០ពាន់លានដុល្លារនៅខែសីហា រីឯរបស់ជប៉ុនថយចុះ ៦% ដល់ ៤៦,៨២ពាន់លានដុល្លារ ។

In August, US goods exports increased, while those from the Euro-zone and Japan decreased. US exports increased by 2 percent, from $75.06 billion in July to $76.67 billion in August. Exports of capital goods, automobile vehicles, parts and engines, industrial supplies and materials, food and beverages registered growth. Exports from the Euro- zone in August decreased from $89.11 billion in July to $83.40 billion in August. Japan's exports in August registered a 6 percent decline from the previous month, to $46.82 billion.

**Exports of Goods in the US, Euro-zone and Japan** (US$ billion)




Sources: BEA, Eurostat and JETRO

នៅខែសីហា ការនាំចេញទំនិញពីកូរ៉េខាងត្បូង និងតៃវ៉ាន់ កើនបន្តិចធៀបនឹងខែមុន ។ ការនាំចេញរបស់កូរ៉េខាងត្បូងកើន ០,៥% ដល់ ២៣,៣៤ពាន់លានដុល្លារ ដោយសារកំណើនផលិតផលនាំចេញគ្រប់ប្រភេទ លើកលែងតែទំនិញកម្មន្តសាល ម៉ាស៊ីន សំភារៈដឹកជញ្ជូន ម្ហូបអាហារ និងសត្វរស់ ។ ការនាំចេញរបស់តៃវ៉ាន់កើន ៣% ដល់ ១៥,៨៥ពាន់លានដុល្លារ ក្នុងនេះការនាំចេញសត្វ និងផលិតផលពីសត្វ បន្លែ និងគ្រឿងគីមី ថយចុះ រីឯផលិតផលជាម្ហូបអាហារ ភេសជ្ជៈ ថ្នាំជក់ និងប្លាស្ទិក កើនឡើង ។

In August, exports of goods from both South Korea and Taiwan increased slightly from the previous month. South Korea's exports rose 0.5 percent to $23.34 billion. Except for manufactured goods, machinery, transport equipment, food and live animals, all production areas registered growth in exports. Taiwan's exports registered a 3 percent increase to $15.85 billion. Exports of animals and animal products, vegetable products and chemicals decreased, while foodstuffs, beverages, tobacco products and plastics increased.

**Exports of Goods by South Korea and Taiwan**
(US$ billion)




Sources: national statistics departments of South Korea and Taiwan

នៅខែសីហា ម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្មដ៏ធំដល់ ២,៥៩ពាន់លានដុល្លារ ធៀបនឹង ១,៥៧ពាន់លាននៅខែកក្កដា ដោយសារការនាំចូលថយចុះ ២% មកត្រឹម ៩,៦៩ពាន់លាន និងការនាំចេញកើន ៧% ដល់ ១២,២៧ពាន់លាន ក្នុងនេះផលិតផលនាំចេញចំបងគឺ ផលិតផលអគ្គិសនី និងអេឡិចត្រូនិក បន្ទាប់មកគឺ ប្រេងឆា ផលិតផលធ្វើពីប្រេងឆា ប្រេងឆៅ ឈើ និងឧស្ម័នធម្មជាតិ ។

In August, Malaysia recorded a trade surplus of $2.59 billion, compared with $1.57 billion in July. The strong growth in the surplus was due to an increase in exports of 7 percent or $0.8 billion and a decrease in imports of 2 percent. Total exports and imports were valued at $12.27 billion and $9.69 billion, respectively. Electrical and electronic products were Malaysia's largest exports, followed by palm oil and palm oil-based products, crude petroleum, timber and liquefied natural gas.

**Malaysia's External Trade January-August 2005**
(US$ billion)




Source: Malaysia External Trade Development Corporation

# ស្ថានភាពអតិផរណានៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់នៅតំបន់អឺរ៉ូ កើន ២,២% ក្នុងរយៈមួយឆ្នាំដល់ចុងខែសីហា ដោយសារកំណើនយ៉ាងច្រើននៃថ្លៃម្ហូបអាហារមិនទាន់កែច្នៃ ទោះបីថ្លៃថាមពលបានចុះបន្តិចក្តី ។ ក្នុងរយៈពេលដដែល ថ្លៃទំនិញប្រើប្រាស់នៅជប៉ុន ថយចុះ ០,៣% (ថយចុះ ៣ខែជាប់គ្នា) ដែលបង្ហាញថា សេដ្ឋកិច្ចជប៉ុន កំពុងជួបបរិត្តផរណាកំរិតទាបមួយ ។ ក្នុងពេលនេះដែរអតិផរណានៅ US ឡើងដល់ ៣,៦% ។

Consumer prices in the Euro-zone rose by 2.2 percent in the year to August, as a substantial rise in prices of unprocessed food offset a slight fall in energy price pressures. During the same period, consumer prices in Japan dropped 0.3 percent, the third consecutive monthly year-on-year decline, signaling that the Japanese economy is in a mild deflationary phase. Meanwhile, US inflation edged up to 3.6 percent in the year to August.

### Inflation Rates in the US, EU and Japan

(percentage change over previous year)




*Note: The latest data available are for August 2005.*
Sources: IMF and the *Economist* (15–21 October 2005)

អត្រាអតិផរណាប្រចាំឆ្នាំបន្តស្ទុះឡើងអស់ ៤ខែជាប់គ្នា ដល់ ១,៤% នៅខែសីហា ។ កំណើនបន្តិចនៃ CPI នៅខែសីហា (ធៀបនឹងខែកក្កដា) បណ្តាលជាសំខាន់មកពីកំណើនថ្លៃឈ្នួលផ្ទះឯកជន និងថ្លៃគ្រឿងអលង្ការ ។ ក្នុងកំឡុងពេលដដែល អត្រាអតិផរណានៅចិនថយចុះមកត្រឹម ២% ឯនៅកូរ៉េខាងត្បូង វាចុះមកត្រឹម ១,៣% ។

Hong Kong’s year-on-year inflation continued to accelerate for the fourth consecutive month, reaching 1.4 percent in August. The slightly larger year-on-year increase in the CPI in August (compared to July), was mainly attributable to an increase in private housing rents and the price of jewellery. During the same period, the annual rate of consumer inflation moderated to 2.0 percent in China and eased to 1.3 percent in South Korea.

### Inflation Rates in China, Hong Kong and South Korea

(percentage change over previous year)




*Note: The latest data available are for August 2005.*
Sources: IMF and the *Economist* (15–21 October 2005)

ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរី កើន ០,៧% ក្នុងរយៈមួយឆ្នាំដល់ចុងខែសីហា ។ យោងតាមនាយកដ្ឋានស្ថិតិ សិង្ហបុរី កំណើននេះឆ្លុះបញ្ចាំងជាសំខាន់ពីការឡើងថ្លៃម្ហូបអាហារ ផ្ទះសំបែង ការអប់រំ សំភារៈការិយាល័យ ការថែទាំសុខភាព និងការលំហែកំសាន្ត ។ ក្នុងកំឡុងពេលដដែល សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅម៉ាឡេស៊ី កើន ៣,៧% ហើយនៅថៃ វាកើន ៥,៧% ។

Singapore’s consumer prices rose by 0.7 percent in the year to August. According to Department of Statistics of Singapore, this increase reflected mainly higher costs of food, housing, education and stationery, health care and recreation. During the same period, the consumer price index rose by 3.7 percent in Malaysia and by 5.7 percent in Thailand.

### Inflation Rates in Selected ASEAN Countries

(percentage change over previous year)




*Note: The latest data available are for August 2005.*
Sources: IMF and the *Economist* (15–21 October 2005)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

# Exchange Rates in World Markets

នៅខែតុលា ២០០៥ ដុល្លារUS បន្តឡើងថ្លៃ ទល់នឹងរូបិយវត្ថុធំបងៗភាគច្រើន ដោយ ១ដុល្លារប្តូរបាន ០,៨៣អឺរ៉ូ រឺ ១១៤,៨២យ៉េន ធៀបនឹង ០,៨២អឺរ៉ូ រឺ ១១០,៩៥យ៉េននៅខែមុន ។ រឿងនេះបណ្តាលជាសំខាន់មកពីការថយចុះការបារម្ភពីការអូសបន្លាយឱនភាពពាណិជ្ជកម្ម និងពីកំណើនគំលាតអត្រាការប្រាក់រវាង US និងតំបន់អឺរ៉ូ ។

In October 2005, the US dollar continued to strengthen against most major currencies. It bought 0.83 euros and 114.82 yen, an appreciation from 0.82 euros and 110.95 yen. This strengthening largely reflected easing of market concerns about the persistence of trade deficits and widening interest rate differentials between the US and the Euro area.

**Euro and Japanese Yen Against the US Dollar**




*Note: Data are to 31 October 2005*
Source: Federal Reserve Bank of New York

ប្រាក់វ៉ុនកូរ៉េខាងត្បូង ចុះថ្លៃអស់ ៣ខែជាប់គ្នា ដោយប្តូរបាន ១០៤៥,៤៧វ៉ុន/ដុល្លារUS រឺចុះថ្លៃ ១,៦% ធៀបនឹងខែកញ្ញា និងចុះថ្លៃ ២,៣%ធៀបនឹងខែសីហា ។ ក្នុងខែដដែល ដុល្លារហុងកុងប្តូរបាន ៧,៧៦ដុល្លារហុងកុង/ដុល្លារUS ។ យោងតាម Reuters ដុល្លារហុងកុង ឡើងថ្លៃដោយសារការប្រមើលឃើញថា នឹងមានលំហូរទុនចូលមកហុងកុងថែមទៀត ។

In October, the South Korean won slid for the third consecutive month against the US dollar, trading at 1045.47, a 1.6 percent depreciation from September and 2.3 percent depreciation since August. The Hong Kong dollar traded at 7.76 against its US counterpart. According to Reuters, the Hong Kong dollar was underpinned by the prospect of further inflow of funds into the territory.

**South Korean Won and Hong Kong Dollar against US Dollar**




*Note: Data are to 31 October 2005.*
Source: Federal Reserve Bank of New York

ប្រាក់បាតឡើងថ្លៃបន្តិច ទល់នឹងដុល្លារ គឺប្តូរបាន ៤០,៨៩បាត/ដុល្លារUS នៅខែតុលា រឺឡើងថ្លៃ ០,៤%ធៀបនឹងខែមុន ។ ប្រាក់បាតឡើងថ្លៃដោយសារមានការវាយស្មានថា ថៃនឹងតំលើងអត្រាការប្រាក់ថែមទៀត ។ ក្នុងពេលជាមួយគ្នា ដុល្លារសិង្ហបុរី ចុះថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ១,៦៩១ដុល្លារសិង្ហបុរី/ដុល្លារUS ធៀបនឹង ១,៦៨១ដុល្លារសិង្ហបុរី/ដុល្លារUS នៅខែកញ្ញា ។

The baht strengthened slightly against the US dollar in October, trading at 40.89 baht/USD, a 0.4 percent appreciation from a month earlier. The baht gained amidst speculation that Thailand would further increase interest rates. Meanwhile, the Singapore dollar slid again against the greenback, depreciating to 1.691 from 1.681 in September.

**Thai Baht and Singaporean Dollar against US Dollar**




*Note: Data are to 31 October 2005.*
Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែកញ្ញា ថ្លៃអង្ករក្នុងពិភពលោកនៅតែខ្ពស់គួរសម ដោយសារតំរូវការនាំចូលមានច្រើន ឯអង្ករសំរាប់នាំចេញមានតិច ។ សន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) កើនដល់ ១១៥,៨ រឺកើនបាន ១,៣ បើធៀបនឹងខែមុន ។ នៅ US អង្ករឡើងថ្លៃពី ២៧៦ដុល្លារ/តោននៅខែសីហា ដល់ ២៨១ដុល្លារ/តោននៅខែកញ្ញា ។ នៅថៃ ការនាំចេញអង្ករកើន ១% នៅខែកញ្ញា ដោយសារការថយចុះអង្ករផ្គត់ផ្គង់ ។ អង្ករធុន Thai 100%B លក់ថ្លៃ ២៩០ដុល្លារ/តោន ធៀបនឹង ២៨៦ដុល្លារ/តោននៅខែសីហា ។

In September, world rice prices remained firm due to a strong import demand and short exportable supply. The international prices index (IPO) rose by 1.3 points from the previous month to 115.8. Rice prices in the US rose from $276 per ton in August to $281. In Thailand, export rice prices grew by 1 percent in September because of declining supply. Thai 100%B was at $290 per ton in September, against $286 per ton in August.

**International Prices Index and Export Rice Prices**
(US$/ton FOB)




Sources: Osiriz/InfoArroz and InterRice.

នៅខែតុលា សណ្តែកសៀងចុះថ្លៃ ឯពោតឡើងថ្លៃ ។ សណ្តែកសៀងលក់ថ្លៃ ២២៥,១៩ដុល្លារ/តោននៅខែតុលា ធៀបនឹង ២២៦,៩០ដុល្លារ/តោននៅខែកញ្ញា រឺចុះថ្លៃ ១% ។ ពោតឡើងថ្លៃដល់ ១០១,៥២ដុល្លារ/តោននៅខែតុលា ធៀបនឹង ៩៦,៨៥ដុល្លារ/តោននៅខែកញ្ញា រឺឡើងថ្លៃ ៥% ។ ប្រេងឆាឡើងថ្លៃដល់ ៤២១ដុល្លារ/តោននៅខែកញ្ញា ធៀបនឹង ៤០៧ ដុល្លារ/តោន នៅខែសីហា ។

The price of soybeans declined in October, while the price of maize rose. Soybeans sold at $225.19 per ton in October compared to $226.90 in September, a 1 percent decrease. The price of maize increased by 5 percent from September, from $96.85 per ton to $101.52. The price of palm oil rose to $421 per ton in September from $407 in August.

**International Prices of Soybean, Maize and Palm Oil** (US$/ton FOB)




Source: Food and Agriculture Organisation

នៅខែតុលា ប្រេងឆៅ និងសាំង ចុះថ្លៃ ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ប្រទេស OPEC គឺ ៥៤,៦១ដុល្លារ/ធុង រឺចុះថ្លៃ ៩% ធៀបនឹងខែមុន ប៉ុន្តែឡើងថ្លៃ ២៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ សាំងធម្មតានៅ US Gulf Coast ចុះថ្លៃ ២២% ពី ៦០,៨២សេន/លីត្រនៅខែកញ្ញា ដល់ ៤៧,៥១ សេន/លីត្រនៅខែតុលា ។

In October, the prices of crude oil and gasoline went down. The OPEC countries spot price of crude oil was $54.61 per barrel, a 9 percent decrease from the previous month, but a 26 percent increase from the same month last year. Conventional regular gasoline on the US Gulf Coast fell by 22 percent from the previous month, selling at 47.51 cents per litre, against 60.82 cents per litre in September.

**Prices of Crude Oil and Gasoline**




***Note: Data are up to 30 September** 2005.*
Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច /Economic News

**ធនាគារពិភពលោកតំលើងតួលេខព្យាករណ៍ពីកំនើនសេដ្ឋកិច្ចកម្ពុជា២០០៥:** ធនាគារពិភពលោក បានតំលើងតួលេខព្យាករណ៍ពីកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ២០០៥ ដល់ ៦,១% ពីកំរិតមុនត្រឹម ២,៦% ដោយលើកថា "ការប្រមើលពីសេដ្ឋកិច្ចកម្ពុជាសំរាប់ឆ្នាំ២០០៥ មានលក្ខណៈល្អជាងមុនច្រើនណាស់" ក្នុងនេះកត្តាសំខាន់ គឺការនាំចេញសំលៀកបំពាក់ដែលមានកំរិតខ្ពស់ជាងការរំពឹងទុក ។ ឧស្សាហកម្មកាត់ដេរ គឺជាប្រភពចំណូលរូបិយប័ណ្ណធំជាច់គេរបស់កម្ពុជា ។ របាយការណ៍បានលើកថា "ថ្វីបើការប្រកួតប្រជែងដែលបានកើនឡើងបន្ទាប់ពីកិច្ចព្រមព្រៀងវិស័យកាត់ដេរ និងវាយនភណ្ឌ (MFA) បានផុតកំនត់ទៅ កំពុងដាក់សំពាធលើថ្លៃសំលៀកបំពាក់នាំចេញ ហើយការឡើងថ្លៃប្រេងឥន្ទនៈ កំពុងគាបសង្កត់វិស័យសេដ្ឋកិច្ចឯទៀតៗក្តី ក៏កំនើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០០៥ ត្រូវបានព្យាករណ៍ថា មានប្រមាណ ៦,១% ហើយបន្តមានកំរិតប្រហែល ៦% នៅឆ្នាំ២០០៦ ទៀត ។ ក្នុងពេលជាមួយគ្នា វិស័យមិនមែនកាត់ដេរផ្សេងៗរបស់កម្ពុជា ដូចជា ទេសចរណ៍ ទូរគមនាគមន៏ និងសំណង់ ក៏បានបន្តរីកលូតលាស់ដែរ ។

**ADB អនុម័តផ្តល់ជំនួយ ១៨លានដុល្លារដល់កម្ពុជា:** ជំនួយនេះ គឺដើម្បីដោះស្រាយបញ្ហាទឹកស្អាត និងអនាម័យ សំរាប់ប្រជាជនដែលរស់នៅជុំវិញបឹងទន្លេសាប ដោយកសាងសំណង់ផ្គត់ផ្គង់ទឹក និងអនាម័យសំរាប់មនុស្សជាង ១លាននាក់ នៅក្នុងខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ពោធិសាត់ និងសៀមរាប ។ សេដ្ឋវិទូម្នាក់របស់ ADB និយាយថា "គំរោងនឹងជួយកែលំអកំរិតជីវភាពនិងសុខភាពរបស់ប្រជាជននៅតាមជនបទ ដែលកំពុងជួបគ្រោះថ្នាក់ដោយសារការប្រើប្រាស់ទឹកមិនស្អាត និងកង្វះអនាម័យ" ។

***ADB: ការកើតមានជំងឺផ្តាសាយបក្សីរយៈពេលយូរ អាចធ្វើឱ្យធ្លាក់ចុះសេដ្ឋកិច្ចជាសាកល:*** របាយការណ៍ថ្មីមួយរបស់ ADB បានលើកថា ការឆ្លងរាលដាលជំងឺផ្តាសាយបក្សីក្នុងរយៈពេលយូរ អាចធ្វើឱ្យមានការធ្លាក់ចុះសេដ្ឋកិច្ចជាសាកល និងធ្វើឱ្យអាស៊ីខាតបង់អស់ប្រហែល ២៨៣ពាន់លានដុល្លារ ។ "ការឆ្លងរាលដាលជំងឺ ប្រហែលនឹងពន្យឺត រឺបញ្ឈប់ ការលូតលាស់សេដ្ឋកិច្ចនៅអាស៊ី និងកាត់បន្ថយពាណិជ្ជកម្មយ៉ាងច្រើន ជាពិសេសខាងផ្នែកសេវាកម្ម" ។ របាយការណ៍ "ផលប៉ះពាល់សេដ្ឋកិច្ចជាយថាហេតុនៃការឆ្លងរាលដាលជំងឺផ្តាសាយបក្សីនៅអាស៊ី" នេះ លើកទៀតថា ជំងឺផ្តាសាយបក្សីអាចបង្កការខូចខាតយ៉ាងច្រើនដល់សេដ្ឋកិច្ច ជាពិសេសក្នុងវិស័យកសិកម្ម និងដោយឡែក ការចិញ្ចឹមមាន់ទា ។ តាមការប៉ាន់ស្មានមួយ វិស័យចិញ្ចឹមសត្វនៅកម្ពុជា ថៃ និងវៀតណាម នឹងត្រូវខាតបង់អស់ ៥៦០លានដុល្លារ ។ របាយការណ៍លើកថា កំនើនក្នុងតំបន់ នឹងធ្លាក់ចុះមកត្រឹម ០,១% និងក្នុងពិភពលោកមកត្រឹម ០,៦% ។ វិនិយោគដុល នឹងធ្លាក់ចុះយ៉ាងតិច ២ឆ្នាំក្នុងប្រទេសអាស៊ីភាគច្រើន ហើយឧស្សាហកម្ម និងពាណិជ្ជកម្មក៏ដូចគ្នាដែរ ។

***World Bank raises Cambodia's growth forecast for 2005:*** The World Bank Thursday upgraded its economic growth forecast for Cambodia in 2005 to 6.1 percent, from 2.6 percent, saying "Cambodia's economic prospects for 2005 have improved considerably". Garment exports being higher than originally expected have contributed to the improved economic prospects, according to the latest edition of the World Bank's twice-yearly economic survey of east Asia and the Pacific. The garment industry is the single largest foreign exchange earner for Cambodia. The report said, "Though increased competition after expiry of the Multifibre Arrangement (MFA) is putting downward pressure on garment export prices and higher oil prices are dampening other sectors of the economy, Cambodia's projected growth for 2005 will be around 6.1 percent. Growth is expected to continue to be at about 6 percent in 2006". Meanwhile, Cambodia's non-garment industrial sectors, such as tourism, telecommunications and construction, have continued to expand. *(Cited from XinhuaNet, 11 August 2005)*

***ADB approves $18 million aid to Cambodia:*** Cambodia is to get an $18 million grant from the Asian Development Bank to provide clean water and sanitation to people living around the Tonle Sap Lake, the Philippines-based lender said. The grant would provide rural water supply and sanitation facilities to more than a million people from Battambang, Kompong Chhnang, Kompong Thom, Pursat and Siem Reap provinces who live around the Lake. "The project will improve the quality of life and health of rural Cambodians, who have suffered greatly from using water unfit for human consumption and from poor hygiene", said ADB project economist Alfredo Perdiguero. *(Cited from AFP, 24 October 2005).*

***ADB: Prolonged bird flu outbreak may cause global recession:*** The Asian Development Bank said in its recently released report that a prolonged avian influenza pandemic could force the world into recession and cost Asia around $283 billion. "A pandemic will likely slow or halt economic growth in Asia and lead to a significant reduction in trade, particularly of services", said the report, "Potential Economic Impact of an Avian Flu Pandemic on Asia". The report said bird flu has already caused significant economic damage, mainly in the agricultural sector and in particular poultry production. One estimate puts the direct cost to the livestock sector in Cambodia, Thailand and Vietnam at $560 million. The report said regional growth would fall to around 0.1 percent while global growth would shrink to 0.6 percent. Gross investment would drop in most Asian countries for at least two years, along with industrial production and trade. *(Cited from Channel NewsAsia International, 3 November 2005).*